## ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ: ៣៦៤ សហវ.ប្រក

រាជធានីភ្នំពេញ,ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ២០០២

# ប្រកាស
## ស្តីពី
## ការបង្កើត និងដាក់ឱ្យដំណើរការនូវទីស្នាក់ការគយនិងរដ្ឋាករមួយចំនួន តាមបណ្តាខ័ណ្ឌនានានៃ រាជធានីភ្នំពេញ

---

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៦៩ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការចាត់តាំងនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ លេខ នស / រកត /១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញច្បាប់ស្តីពីពន្ធលើទំនិញនាំចេញ និងនាំចូល ដែលប្រកាសឱ្យប្រើដោយក្រឹត្យលេខ ៥៧ ក្រ ចុះថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ១៩៨៩ របស់ក្រុមប្រឹក្សារដ្ឋ
- យោងចំណារឯកភាពរបស់សម្តេចនាយករដ្ឋមន្ត្រី ចុះថ្ងៃទី ០៤ ខែមេសា ឆ្នាំ២០០២ លើសំណើលេខ ១២៩១ សហវ ចុះថ្ងៃទី ០៣ ខែមេសា ឆ្នាំ២០០២ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ចុះថ្ងៃទី ខែ ឆ្នាំ២០០២ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការបង្កើត និងដាក់ឱ្យដំណើរការនូវសាខាគយនិងរដ្ឋាករ រាជធានីភ្នំពេញ
- យោងការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សំរេច

**ប្រការ១ :** បង្កើត និងដាក់ឱ្យដំណើរការនូវទីស្នាក់ការគយនិងរដ្ឋាករមួយចំនួនដែលបានបោះប្រចាំតាមបណ្តាខ័ណ្ឌនៃ រាជធានីភ្នំពេញ ថ្នាក់ប្រហាក់ប្រហែល ការិយាល័យនានាជុំវិញខេត្ត ក្រុង ដែលស្ថិតនៅក្រោមការដឹកនាំផ្ទាល់របស់សាខាគយនិងរដ្ឋាករ រាជធានីភ្នំពេញមានដូចខាងក្រោម៖

១- ទីស្នាក់ការគយនិងរដ្ឋាករ ខ័ណ្ឌ ៧ មករា

២- ទីស្នាក់ការគយនិងរដ្ឋាករ ខ័ណ្ឌ ដូនពេញ

៣- ទីស្នាក់ការគយនិងរដ្ឋាករ ខ័ណ្ឌ ចំការមន

៤- ទីស្នាក់ការគយនិងរដ្ឋាករ ខ័ណ្ឌ ទួលគោក

៥- ទីស្នាក់ការគយនិងរដ្ឋាករ ខ័ណ្ឌ មានជ័យ

៦- ទីស្នាក់ការគយនិងរដ្ឋាករ ខ័ណ្ឌ ដង្កោ

៧- ទីស្នាក់ការគយនិងរដ្ឋាករ ខ័ណ្ឌ ឫស្សីកែវ

**ប្រការ ២** : ទីស្នាក់ការគយនិងរដ្ឋាករនីមួយៗដូចមានចែងក្នុងប្រការ១ខាងលើដឹកនាំដោយប្រធានទីស្នាក់ការមួយរូប និងមានអនុប្រធានទីស្នាក់ការមួយចំនួនជាជំនួយការ ។

**ប្រការ ៣** : ទីស្នាក់ការគយនិងរដ្ឋាករនីមួយៗតាមបណ្តាខ័ណ្ឌនៃ រាជធានីភ្នំពេញ មានភារកិច្ចដូចតទៅ ៖

១- ចុះស្រង់ កសាងនិងកែសំរួលបញ្ជីជំរឿនស្ថិតិ អាជីវកម្មដ្ឋានលក់ដុំ លក់រាយ ភណ្ឌាគារសន្និធិទំនិញនានា ដែលស្ថិតក្រោមប្រពន្ធ័គ្រប់គ្រងពិសេស រួមមាន យានយន្តគ្រប់ប្រភេទ ផលិតផលគេលសិលា ភេសជ្ជៈ ព្រមទាំងទំនិញរសើបមួយចំនួនទៀតដែលកំណត់ដោយទីចាត់ការគយនិងរដ្ឋាករ ។

២- ស្រាវជ្រាវ ទប់ស្កាត់ និងបង្ក្រាបរាល់បទល្មើសគយនានាក្នុងភូមិសាស្ត្រគ្រប់គ្រងរបស់រាជធានីភ្នំពេញ លើទំនិញនាំចូលដោយគេចពន្ធតាមគ្រប់រូបភាពដែលកំពុងសន្និធិចរាចរ ចែកចាយ ឬ កំពុងប្រើប្រាស់តាមបណ្តាអាជីវកម្មដ្ឋាន ភណ្ឌាគារទំនិញ មូលដ្ឋានផលិតកម្ម ឬលំនៅដ្ឋាននានា ដោយអនុលោមតាមនីតិវិធីច្បាប់ និងបទបញ្ញត្តិនានាជាធរមាន ។

៣- អនុវត្តតាមភារកិច្ចផ្សេងៗដែលនឹងកំណត់តាមការចាំបាច់នានា ដោយទីចាត់ការគយនិងរដ្ឋាករស្របតាមបញ្ញត្តិច្បាប់ជាធរមាន ។

៤- ប្រើប្រាស់កំលាំងគយនិងរដ្ឋាករក្រោមឱវាទ ដោយសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចប្រចាំមូលដ្ឋាន ជាពិសេសអាជ្ញាធរដែនដីគ្រប់ជាន់ថ្នាក់ ក្នុងករណីចាំបាច់ ដើម្បីសំរេចឱ្យបាននូវភារកិច្ចដូចរៀបរាប់ខាងលើ ។

**ប្រការ ៤** : ប្រកាសទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៥** : អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកទីចាត់ការគយនិងរដ្ឋាករ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាន និងអង្គភាពពាក់ពន្ធ័ផ្សេងទៀត នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានភារកិច្ចអនុវត្តតាមប្រកាសនេះឱ្យមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**គាត ឈន់**

**ចម្លងជូន** :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ ( ដើម្បីជូនជ្រាប )
- សាលាក្រុងភ្នំពេញ
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ( ដើម្បីសហការអនុវត្ត )
- ដូចប្រការ៥ ( ដើម្បីអនុវត្ត )
- ឯកសារ-កាលប្បវត្តិ